acara AUSTRALIAN CURRICULUM, ASSESSMENT AND REPORTING AUTHORITY

# ការជូនដំណឹងស្តីពី ការសំងាត់ឯកជន

## ពត៌មានដែលត្រូវការដើម្បីកំណត់សន្ទស្សន៍នៃអត្ថប្រយោជន៍របស់សហគមន៍ក្នុងផ្នែកអប់រំ-សង្គមកិច្ច (ICSEA) សំរាប់សាលារៀននានា

ការជូនដំណឹងនេះគឺមកពីអាជ្ញាធរអូស្ត្រាលីទទួលបន្ទុកកម្មវិធីសិក្សា ការវាយតម្លៃ និងការធ្វើរបាយការណ៍ (ACARA) ដើម្បីណែនាំលោកអ្នកថា ACARA  បានស្នើរសុំសាលារៀនរបស់កូនលោកអ្នកដើម្បីផ្តល់ឲ្យ ACARA នូវពត៌មានអំពីលោកអ្នកនិងកូនរបស់លោកអ្នក។ សាលារៀនរបស់លោកអ្នកអាចបញ្ជូន ទៅឲ្យ ACARA នូវពត៌មានដូចជាភេទរបស់កូនលោកអ្នក ថ្ងៃ ខែ កំណើត ប្រទេសកំណើត សាវតាភាសា អាស័យដ្ឋានផ្ទះ មុខរបរ និងការអប់រំរបស់ឪពុកម្តាយ។

ពត៌មាននេះត្រូវបានបញ្ជូនទៅឲ្យ ACARA នៅក្រោមច្បាប់ *ACARA 2008* សំរាប់គោលបំណងមួយ ឬគោលបំណងទាំងពីរនៃបណ្តាគោលបំណងដូចតទៅ:

- រៀបចំបង្កើតនូវរបាយការណ៍ថ្នាក់ជាតិដែលរួមមាន ទិន្នន័យបូកសរុបលើការអនុវត្តន៍របស់សាលារៀន និង
- ជួយរដ្ឋាភិបាលដើម្បីរៀបចំបង្កើតនូវគោលនយោបាយនានាទាក់ទងទៅនឹងបញ្ហាការអប់រំនានា។

ACARA នឹងមិនបញ្ជូនពត៌មានផ្ទាល់ខ្លួននេះទៅភាគីទីបីណាមួយទេ។ ប្រសិនបើលោកអ្នកមិនចង់ឲ្យសាលារៀនរបស់លោកអ្នកផ្តល់នូវពត៌មាននេះទៅឲ្យ ACARA ទេ សូមប្រាប់សាលារៀនរបស់លោកអ្នកនៅក្នុងអំឡុងពេល ប្រាំពីរ (7) ថ្ងៃ នៃការទទួលបានការជូនដំណឹងនេះ។

សំរាប់ពត៌មានថែមទៀតអំពី ACARA អាចទទួលបានពីគេហៈទំព័ររបស់ ACARA នៅឯ www.acara.edu.au ។